# ការថែទាំកូនជ្រូក កំពុងផ្ដាច់ដោះ



រៀបរៀងឡើងដោយគណៈកម្មការផលិតកម្ម និងបសុព្យាបាលខេត្តតំបន់តាយ៉ៀ

ឧបត្ថម្ភដោយអង្គការ យូអិនឌីភី/យូអិនអូភីអេស/ឃែរ៉េរ៉េ (UNDP/UNOPS/CARERE)

ថតចម្លងលើកទីមួយ; ឆ្នាំ 1997

# ការថែទាំកូនជ្រូកបៅដោះ

## មាតិការឿង


① អាការៈមេជ្រូកមុនពេលកើតកូន....................................................1

បណ្ដាអាការៈបង្ហាញឡើងពេលមេជ្រូកជិតកើតកូន.....................................1

② ការថែទាំកូនជ្រូកទើបនឹងកើត....................................................2

③ ផ្ដល់កំដៅអោយកូនជ្រូក....................................................4

④ អោយកូនជ្រូកបៅដោះ....................................................5

⑤ បន្ថែមជាតិដែកអោយកូនជ្រូក....................................................11

⑥ ការផ្ដាច់ដោះកូនជ្រូក....................................................12

⑦ ក្រៀវកូនជ្រូក និងចាក់ថ្នាំការពារអោយកូនជ្រូក..............................13

⑧ បណ្ដាមូលហេតុបង្កនូវភាពរាគរូសទៅលើកូនជ្រូក និងការដោះស្រាយ......13

⑨ តម្រូវការអំពីទ្រុង....................................................15

** ឯកសារយោង....................................................16

** ឈ្មោះគណៈកម្មការផលិតកម្ម និងបសុព្យាបាលខេត្តតំបន់ពាយ័ព្យ

# អារម្ភកថា

បើនិយាយអំពីការចិញ្ចឹមជ្រូកប្រជាពលរដ្ឋកម្ពុជាយើង មានប្រពៃណីចិញ្ចឹមតាំងពីយូរលង់ណាស់មកហើយ ។ រហូតមកដល់សព្វថ្ងៃនេះ ប្រពៃណីចិញ្ចឹមនេះនៅតែប្រកាន់ខ្ជាប់នៅតាមគ្រួសារកសិករ ។ គ្រួសារកសិករភាគច្រើននៅតាមជនបទរហូតដល់ជាយទីក្រុងមានចិញ្ចឹមជ្រូក គិតជាមធ្យមពី 2-5 ក្បាល មួយក្នុងគ្រួសារ ។ ប៉ុន្តែការចិញ្ចឹមនេះនៅមានលក្ខណៈជាយថាផលនៅឡើយគឺចិញ្ចឹមបានប៉ុណ្ណាយកប៉ុណ្ណោះ ។

ឈានចូលដល់សម័យវិទ្យាសាស្ត្របច្ចេកទេសជឿនលឿន ការចិញ្ចឹមសត្វគេត្រូវចិញ្ចឹមទៅតាមបែបផែនបច្ចេកទេស គេត្រូវធ្វើការគណនាចាំទុកប្រមាណអំពីផលចំណេញទុកជាមុន ។ ដើម្បីមានចំណេះដឹងគេត្រូវយល់ដឹងអំពីបច្ចេកទេសការចិញ្ចឹមអោយបានសមស្របជាទីបំផុត ។

ដើម្បីរួមចំណែកនូវចំណោះស្រាយសំណួរខាងលើ យើងខ្ញុំនិងចងក្រងសៀវភៅតូចនេះឡើងអំពីបច្ចេកទេសការថែទាំកូនជ្រូកកំពុងបៅដោះ សំរាប់ទុកធ្វើការផ្សព្វផ្សាយដល់ប្រជាកសិករនៅខេត្តតំបន់ពាយ័ព្យនៃព្រះរាជាណាចក្រកម្ពុជាយើង ហើយដែលកន្លងមកបច្ចេកទេសនេះបានអនុវត្តន៍នៅទីរួមខេត្តបន្ទាយមានជ័យ ហើយទទួលបាននូវលទ្ធផលខ្ពស់គួរអោយចាប់អារម្មណ៍ ។

ការថែទាំកូនជ្រូកកំពុងបៅដោះគឺជាបញ្ហាស្មុគ្រស្មាញ ដែលអ្នកចិញ្ចឹមជ្រូកភាគច្រើនតែងជួបប្រទះដូចជា : កូនជ្រូកកើតជំងឺរាគរូស លាមកពណ៌ស ញៀង ប្រផេះ ហើមពោះ បាក់កម្លាំង ទ្រុឌទ្រោម គ្រិន ចិញ្ចឹមក្រធំ ។ល។ បញ្ហាទាំងនេះនិងអាចដោះ-

ស្រាយបានលុះណាតែអ្នកចិញ្ចឹមអនុវត្តន៍អោយបានត្រឹមត្រូវ និងពីណាក់កាលរីកលូត-លាស់របស់កូនជ្រូកត្រូវធ្វើយ៉ាងណាខ្លះ ? កូនជ្រូកត្រូវការអ្វីខ្លះ ? ដើម្បីចិញ្ចឹមជីវិតអោយបានធំធាត់ និងពោពេញទៅដោយសុខភាព ។

យើងខ្ញុំសង្ឃឹមថាសៀវភៅដ៏ស្តើងនេះ ចាត់ទុកជាការបង្ហាញបច្ចេកទេសដែលមានផលប្រយោជន៍ ហើយផ្សារភ្ជាប់យ៉ាងជិតស្និទ្ធនិងអ្នកចិញ្ចឹមជ្រូក ។

គណៈកម្មការយើងខ្ញុំសង្ឃឹមថា និងទទួលបាននូវមតិយោបល់រួមចំណែកជាច្រើនរបស់មិត្តអ្នកអាន ដើម្បីកែលំអរសៀវភៅនេះពីមួយថ្ងៃទៅមួយថ្ងៃកាន់តែប្រសើរឡើង ។

គណៈកម្មការអភិវឌ្ឍន៍វិស័យផលិតកម្ម
និង បសុព្យាបាលខេត្តតំបន់ពាយ័ព្យ

# ការថែទាំកូនជ្រូកបៅដោះ

## ❶ អាការៈមេជ្រូកមុនពេលកើតកូន

រយៈពេលផើមរបស់ជ្រូកគឺ 114-115 ថ្ងៃ (3 ខែ 3 អាទិត្យ 3 ថ្ងៃ) ។ ថ្ងៃកើតកូនមានការប្រែប្រួល 1-2 ថ្ងៃ (អាចរហ័សជាង ឬយឺតជាង 1-2 ថ្ងៃ) ករណីពិសេសមានមេជ្រូកកើតកូនយឺតរហូតដល់ 7-10 ថ្ងៃ ។

*បណ្ដាអាការៈបង្ហាញឡើងពេលមេជ្រូកជិតកើតកូន :*

ដើរចុះឡើងយ៉ាងពិបាក ដំណើរត្រឹមត្រូម កន្សោមដោះឡើង តឹងមានពណ៌ក្រហមស្រស់ យកដៃច្បួតមានចេញទឹកដោះ ។ មេជ្រូកកាច់សំបុក ឈ្ងុសស្នូក ឈ្ងួសទ្រុង ជុះអាចម៍បន្តបន្ទាប់ លាមករឹងប៉ុនៗម្រាមដៃ ។ ពេលបែកទឹកភ្លោះហូរចេញមក (ទឹករំអិលខាប់អន្ទិល ឬមានអាចម៍ព្រៃរបស់កូនជ្រូកហូរចេញមកជាមួយ) គឺជាពេលកូនជ្រូកជិតកើតចេញមក ។ មេជ្រូកកូនដំបូង (កូនលើកទីមួយ) ច្រើនកើតពិបាកជាងមេជ្រូកចាស់ (សំរាលកូនលើសពី 2 ដងឡើងទៅ) ជាធម្មតាគីរាល់ក្រោយពេលប្រឹងយ៉ាងខ្លាំងម្ដងៗ មេជ្រូករួញកន្ទ្រាក់ជើងក្រោយឡើង គឺពេលនោះដែលកូនជ្រូកត្រូវបានមេប្រឹងជំរុញចេញមកក្រៅ ធម្មតាជាមធ្យមពី 10-15 នាទី 15 នាទី ទៅមួយម៉ោង មេជ្រូកបង្កើតបានកូនមួយក្បាល ។ មានករណីមេជ្រូកកើតបន្តបន្ទាប់ 2-3 ក្បាល ក្នុងរង្វង់ 10 នាទី ។ បើសិនមេជ្រូកបង្កើតកូនស្រួលគ្រាន់តែក្រោយ 2-5 ម៉ោង គឺបង្កើតកូនរួច និងក្រោយ 2-3 ម៉ោង សុកនឹងធ្លាក់ចេញមកអស់ ។

ក្នុងពេលដែលកូនជ្រូកកើតចេញពីពោះមេ អាចក្បាលកើតចេញមកមុន ឬជើងក្រោយពីចេញមកមុន កើតមកបន្តបន្ទាប់គ្មានអ្វីជាគ្រោះថ្នាក់ទេ ។ ប៉ុន្តែក្នុងករណីដែលមេជ្រូកបានបែកទឹកភ្លោះ 3-6 ម៉ោង ហើយមិនឃើញកូនជ្រូកកើតចេញមកត្រូវតែទៅរកអ្នកបច្ចេកទេស បសុពេទ្យមកធ្វើអន្តរាគមន៍ ។

❷ <u>ការថែទាំកូនជ្រូកទើបនឹងកើត</u>

ពេលកូនជ្រូកកើតចេញមកពីពោះមេ អាចកើតក្បាលចេញមកមុន ឬជើងក្រោយ 2 ចេញមកមុន ។ នៅក្នុងពោះមេកូនជ្រូកទំលាយស្រោមសុកដោយខ្លួនវា និងកើតចេញមកក្រៅ ។ ករណីខ្លះកូនជ្រូកកើតមកទាំងស្រោម យើងចាំបាច់ប្រញាប់ប្រញាល់ហែកទំលាយស្រោម ដើម្បីយកកូនចេញមកកុំអោយកូនជ្រូកថប់ដង្ហើម ។

កូនជ្រូកកើតមកភ្លាមប្រឡាក់ប្រឡូសដោយទឹករំអិល យើងត្រូវចាប់លើកកូនជ្រូកមួយៗ យកកន្សែងស្អាតមកជូតជំរះទឹករំអិលក្នុងមាត់ ច្រមុះ និងខ្លួនអោយបានស្អាត ប្រើសសៃអំបោះត្រាំក្នុងអាល់កុលចងទងផ្ចិត ចន្លោះពីពោះ 3 សង្ទីម៉ែត្រ រួចហើយយកកន្ត្រៃស្អាត (ជូតជំរះដោយអាល់កុល) កាត់ទងផ្ចិតឃ្លាតពីចំណុចចង 2 សង្ទីម៉ែត្រ ជូតសំអាតកន្លែងកាត់ដោយថ្នាំក្រហម ឬអាល់កុលអ៊ីយ៉ូត ប្រើកន្ត្រៃកាត់ក្រចក ឬកន្ត្រៃសំរាប់កាត់ធ្មេញ កាត់ធ្មេញស្រួចទាំង 8 របស់កូនជ្រូក (ធ្មេញ 4 ខាងលើ ធ្មេញ 4 ខាងក្រោម) កាត់យកចេញផ្នែកស្រួចពីរភាគបីនៃធ្មេញ ធ្វើយ៉ាងណាកុំអោយមុតរបួសអញ្ចាញធ្មេញ ។ ការកាត់ធ្មេញកាន់តែរហ័សគឺកាន់តែល្អ (កុំអោយលើសពី 24 ម៉ោង ក្រោយពេលកើត) ពីព្រោះពេលនោះធ្មេញនៅទន់ ឈាមហូរតិច ។ ផលប្រយោជន៍នៃការកាត់ធ្មេញ ដើម្បីជៀសវាងកុំអោយកូនជ្រូកខាំដោះមេវា និងខាំដណ្តើមគ្នានៅពេលដែលវាបៅដោះមេរបស់វា ។



## ❸ ផ្តល់កំដៅអោយកូនជ្រូក




- កូនជ្រូកទើបនឹងកើត ក្រោយពេលកាត់ផ្ចិត កាត់ធ្មេញរួចត្រូវយកដាក់ទ្រុង (ធុង) ដើម្បីផ្តល់កំដៅដល់កូនជ្រូក ។

- ក្នុងរដូវក្តៅ ផ្តល់កំដៅអោយកូនជ្រូកមួយអាទិត្យ ក្រោយមកគ្រាន់តែផ្តល់កំដៅអោយនៅពេលយប់ក្នុងរយះពេល 2 អាទិត្យ ។
- ក្នុងរដូវភ្លៀងត្រូវផ្តល់កំដៅអោយកូនជ្រូកក្នុងរយះពេល 2 អាទិត្យ ។
- ទ្រុង (ធុង) ផ្តល់កំដៅត្រូវរៀបចំអោយធំល្មមទំហំ (1ម៉ែត្រ x 1ម៉ែត្រ 0.5 ម៉ែត្រ) ដោយមានក្រាលចំបើង ឬស្លឹកចេកងាប់ ឬក្រណាត់ ចាស់ៗស្អុត ប្រើអំពូលអគ្គិសនី 75-100 វ៉ាត់ ឬប្រើចង្កៀងប្រេងកាតដែលមានអំពូងការពារខ្យល់ ចង្ក្រានធ្យូង ទៅកំដៅអោយកូនជ្រូក ។
- អំពូលអគ្គិសនីត្រូវដាក់កំពស់ 30 សង្ទីម៉ែត្រ ប្រើចង្កៀង ឬចង្ក្រានធ្យូងត្រូវមានដាក់ប្រដាប់ឃាំង ដើម្បីការពារកុំអោយកូនជ្រូកឆេះរលាកបាន ។

## ❹ អោយកូនជ្រូកបៅដោះ

ក. ទឹកដោះដំបូង :

ទឹកដោះដំបូងគឺជាទឹកដោះដែលមេជ្រូកបញ្ចេញ 2-3 ថ្ងៃ ដំបូងក្រោយពេលបង្កើតកូនរួច ។ ទឹកដោះដំបូងមានសារៈជាតិចិញ្ចឹមកូនបានគ្រប់គ្រាន់ និង អង់ទីគ័រ សំរាប់ប្រឆាំងទល់ទល់និងជំងឺអោយកូនជ្រូកដោយមេជ្រូកបញ្ជូនតាមរយះទឹកដោះរបស់វា ។

កូនជ្រូកត្រូវតែបានបៅទឹកដោះដំបូងរបស់មេបង្កើតរបស់វា ។ បើចង់បញ្ជូនកូនជ្រូកទើបតែកើតមកពីមេរបស់វានោះ ទៅអោយមេផ្សេងចិញ្ចឹមចាំបាច់ត្រូវតែអោយបណ្តាកូនជ្រូកទាំងនោះ បានបៅទឹកដោះដំបូងមេបង្កើតរបស់វាអោយបានរយះពេល 1-2 ថ្ងៃ សិន ។

- ត្រូវដាក់កូនថ្លុកទៅអោយនៅជោះមេរបស់វាប្រមាណ ?
  ពេលដែលកូនថ្លុកបានកើតចេញពីពោះរបស់មេវា ។
- ក្នុងថ្ងៃដំបូងត្រូវអោយកូនថ្លុកទាំងអស់នៅទឹកដោះដំបូង
- ពេលថ្ងៃអោយនៅ 2 ម៉ោង ម្តង រយៈពេលនៅគឺ 10-
- ពេលយប់អោយនៅក្នុងរយៈពេលពី 3-4 ម៉ោង ម្តង ។
- ចាប់ពី 2 អាទិត្យឡើងទៅអោយកូនថ្លុកនៅដោយសេរី

ខ. <u>បង្ហាត់កូនថ្លុកអោយស៊ីចំណី</u> :

- កើតមកបានរយៈពេល 7 ថ្ងៃ គឺត្រូវចាប់ផ្តើមបង្ហាត់កូន
  ស៊ីបបរជាបណ្តើរៗ ថែមកន្ទក់ម៉ដ្ឋ ឬចំណីអាហារឲ្យ
  ថ្លុកស៊ី ។
- ជារៀងរាល់ថ្ងៃត្រូវបង្ហាត់កូនថ្លុកអោយវាស៊ី 3 ដង :
  ល្ងាច ផ្លាស់គ្នាពេលនៅដោះ ។
- ចាប់ផ្តើមពីអាទិត្យទី 4 អោយវាស៊ីបន្លែ ដល់ 6-7 អា
  ដែលត្រូវផ្តាច់ដោះ ។

គ. <u>វិធីបង្ហាត់អោយកូនបេះស៊ីចំណី</u> : យើងកូនថ្លុកដាក់ដោយឡែ
កូនថ្លុកមានស្នូកចំណី ។ ថ្ងៃដំបូងយើងអាចយកចំណីទៅ
យ៉ាងនេះ 3 ទៅ 4 ដង ឬយកចំណីផ្សើម ទឹកតិចៗ
អោយបាន 3-4 ដង ធ្វើរបៀបនេះថ្លុកនិងស៊ីចំណីក្រោយ




ទ្រុងកូនជ្រូកនៅផ្សេង និងមានស្នូកចំណីនៅផ្សេង

## ✱ ការណែនាំសមាសធាតុអាហារផ្សំមួយចំនួនសំរាប់បង្ហាត់អោយកូនជ្រូកស៊ី

ក. <u>សមាសធាតុចំណីអាហារសំខាន់គឺ</u> : ពោតក្រហម + កន្ទក់ម៉ដ្ឋ + សណ្ដែកសៀង + ម្សៅត្រី

| សមាសធាតុ | កូនជ្រូកទំងន់ 5 គីឡូក្រាម | | កូនជ្រូកទំងន់ 5-20 គីឡូក្រាម | |
|---|---|---|---|---|
| | គិតជាភាគរយ % | គិតក្នុង 10 គ.ក ចំណី | គិតជាភាគរយ % | គិតក្នុង 10 គ.ក ចំណី |
| កន្ទក់ ពោតក្រហម | 46.75 | 4.7 | 42.75 | 4.3 |
| កន្ទក់ម៉ដ្ឋ | 18 | 1.8 | 25 | 2.5 |
| ម្សៅត្រី | 15 | 1.5 | 14 | 1.4 |
| សណ្ដែកសៀងលីង (ម៉ដ្ឋ) | 20 | 2.0 | 18 | 1.8 |
| ប្រេម៉ិច+ វិតាមីន+ ធាតុរ៉ែ | 0.25 | 0.025 | 0.25 | 0.025 |
| **សរុបទាំងអស់ :** | **100%** | **10 គ.ក** | **100%** | **10 គ.ក** |

---

ខ. <u>សមាសធាតុបន្សំសំខាន់ៗគឺ</u> : ពោតក្រហម + សណ្ដែកសៀង + ម្សៅត្រី

| សមាសធាតុ | កូនជ្រូកទំងន់ 5 គីឡូក្រាម | | កូនជ្រូកទំងន់ 5-20 គីឡូក្រាម | |
|---|---|---|---|---|
| | គិតជាភាគរយ % | គិតក្នុង 10 គ.ក ចំណី | គិតជាភាគរយ % | គិតក្នុង 10 គ.ក ចំណី |
| ពោត | 39.88 | 4.0 | 47.7 | 4.8 |
| សណ្ដែកសៀងលីង | 19.83 | 2.0 | 7.14 | 0.7 |

| | | | | |
|---|---|---|---|---|
| កន្ទក់ម៉ដ្ឋ | 16 | 1.6 | 16 | 1.6 |
| នំកាកសណ្ដែកសៀង | 12.2 | 1.2 | 18.68 | 1.8 |
| ម្សៅត្រី | 10 | 1.0 | 8.0 | 0.8 |
| ម្សៅសំបក លៀសខ្យងខ្ចៅ | 0.78 | 0.07 | 1.2 | 0.1 |
| លីស៊ីន | 0.47 | 0.04 | 0.41 | 0.04 |
| ព្រេមិច | 0.25 | 0.02 | 0.25 | 0.02 |
| មេទីអូនីន | 0.05 | 0.005 | 0 | 0 |
| **សរុបទាំងអស់ :** | **100%** | **10 គ.ក** | **100%** | **10 គ.ក** |
| ថាមពលជាគីឡូកាល់ឡូរី/1Kgចំណី | 3133 | | 3046 | |
| ប្រូតេអ៊ីនសុទ្ធគិតជា % | 23.5 | | 20.6 | |
| កាល់ស្យូមគិតជា % | 0.9 | | 1.0 | |
| ផូស្វរគិតជា % | 0.7 | | 0.7 | |
| ជាតិខ្លាញ់គិតជា % | 7.7 | | 5.7 | |

គ. <u>សមាសធាតុបន្សំសំខាន់គឺ</u> : កញ្ចុងអង្ករ + សណ្ដែកសៀង + ម្សៅត្រី

| សមាសធាតុ | កូនជ្រូកទំងន់ 5 គីឡូក្រាម | | កូនជ្រូកទំងន់ 5-20 គីឡូក្រាម | |
|---|---|---|---|---|
| | គិតជាភាគរយ % | គិតជា 10 គ.ក ចំណី | គិតជាភាគរយ % | គិតជា 10 គ.ក ចំណី |
| កញ្ចុងអង្ករ | 42.4 | 4.2 | 48.59 | 4.9 |

| | | | | |
|---|---|---|---|---|
| សណ្ដែកសៀងលីង | 21.0 | 2.1 | 14.5 | 1.5 |
| កន្ទក់ម៉ដ្ឋ | 16.21 | 1.6 | 16.55 | 1.6 |
| នំកាកសណ្ដែកសៀង | 9.6 | 1.0 | 10 | 1.0 |
| ម្សៅត្រី | 8.0 | 0.8 | 8.0 | 0.8 |
| ម្សៅសំបក ខ្ចៅ ខ្យង | 1.84 | 0.18 | 1.59 | 1.15 |
| លីស៊ីន | 0.55 | 0.05 | 0.42 | 0.04 |
| ប្រេមិច+ វីតាមីន + ធាតុរ៉ែ | 0.25 | 0.02 | 0.25 | 0.02 |
| មេទីអូនីន | 0.08 | 0.008 | 0 | 0 |
| **សរុបទាំងអស់ :** | **100%** | **10 គ.ក** | **100%** | **10 គ.ក** |
| ថាមពលជាតិស្ករកាល់ឡូរី/1Kg ចំណី | 3178 | | 3154 | |
| ប្រូតេអ៊ីនសុទ្ធគិតជា % | 22.1 | | 20 | |
| កាល់ស្យូមគិតជា % | 1.2 | | 1.1 | |
| ផូស្វរគិតជា % | 0.7 | | 0.7 | |
| ជាតិខ្លាញ់គិតជា % | 6.8 | | 5.8 | |

៥ <u>បន្ថែមជាតិដែកអោយកូនជ្រូក</u>

តម្រូវការជាតិដែករបស់ជ្រូកមួយថ្ងៃត្រូវការ 7-9 មិល្លីក្រាម· ប៉ុន្តែបរិមាណជាតិ



ដែកមេជ្រូកផ្គត់ផ្គង់អោយកូនជ្រូកតាមរយៈទឹកដោះបានតែ 1-2 មល្លិក្រាម/ក្នុងកូន ក្នុងមួយថ្ងៃ ៕ ដូច្នេះមួយថ្ងៃកូនជ្រូកខ្វះជាតិដែកពី 6-7 មល្លិក្រាម ៕ ជាតិដែក

ជាធាតុមួយយ៉ាងសំខាន់សំរាប់បង្កើតឈាមក្រហម ។ ដូច្នេះបើសិនជាជ្រូកទទួលជាតិដែកតែតាមរយៈទឹកដោះមេ នោះសារពាង្គកាយរបស់កូនជ្រូកនឹងខ្វះជាតិដែក ធ្វើអោយកូនជ្រូកខ្វះឈាមបណ្តាលអោយខ្វះជីវជាតិទៅជាក្រិន និងភាគស្រស ឈាមកពណ៌ស ។ ដូច្នេះយើងត្រូវចាក់បំពេញជាតិដែកអោយទៅកូនជ្រូកនៅអាយុបាន 3 ថ្ងៃ ហើយចាក់លើកទីពីរនៅអាយុ 21 ថ្ងៃ ។ ការចាក់ថ្នាំនេះអាចទំនាក់ទំនងជាមួយនឹងបសុពេទ្យ ។

## ៦ ការផ្តាច់ដោះកូនជ្រូក

ផ្តាច់ដោះកូនជ្រូករហ័សគឺជាវិធីយ៉ាងសំខាន់ ដើម្បីបង្កើនចំនួនដងបង្កើតកូនជ្រូករបស់មេ នៅប្រទេសអភិវឌ្ឍន៍មួយចំនួនគេផ្តាច់ដោះកូនជ្រូករហ័សគឺក្នុងរយៈពេលអាយុបាន 20-30 ថ្ងៃ ។ ប៉ុន្តែលក្ខខ័ណ្ឌចិញ្ចឹមនៅប្រទេសយើងមានកំរិត ដូច្នេះគម្បីបង្រៀនកូនជ្រូកអោយឆាប់ចេះស៊ីចំណី ហើយផ្តាច់ដោះនៅពេលវាមានអាយុពី 40-50 ថ្ងៃ គឺជាការល្អបុំត ។ ពីព្រោះពេលនោះមានទឹកដោះមេមានការថយចុះ ហើយកូនជ្រូកចេះចាប់ស៊ីចំណីបានច្រើន ។

## វិធីផ្តាច់ដោះកូនជ្រូក

- បង្ហាត់កូនជ្រូកអោយស៊ីចំណីឲ្យចាប់ពីអាយុ 7-8 ថ្ងៃ ឡើងទៅ ស៊ីចំណីផង និងបៅដោះមេវាផង ។
- បង្ខាំងកូនជ្រូកអោយនៅដោយឡែកពីមេ រាល់ពេលអោយកូនជ្រូកបៅដោះ និងស៊ីចំណី ផឹកទឹករួចហើយ ការផ្តាច់ដោះត្រូវអនុវត្តន៍ជាបណ្តើរៗ ។

- បន្ថយចំនួនការបៅក្នុងមួយថ្ងៃ ៖ ថ្ងៃទីមួយអោយបៅ 5 ដង ថ្ងៃទី 2 អោយបៅ 4 ដង ថ្ងៃទី 3 អោយបៅ 3 ដង ថ្ងៃទី 4 អោយបៅ 2 ដង ថ្ងៃទី5 អោយបៅ 1 ដង និងនៅថ្ងៃទី 6 អោយបៅផ្តាច់តែម្តង ។
- អោយកូនជ្រូកស៊ីចំណីតែមួយប្រភេទ មុននឹងក្រោយពេលផ្តាច់ដោះ
- ពេលផ្តាច់ដោះគប្បីអោយកូនជ្រូកនៅក្នុងទ្រូងចាស់ប្រមាណមួយអាទិត្យ នាំមេជ្រូកទៅដាក់ក្នុងទ្រូងផ្សេងទៀត ។

## ❼ ក្រៀវកូនជ្រូក និងចាក់ថ្នាំការពារកូនជ្រូក

- កូនជ្រូកបើសិនមិនទុកធ្វើពូជទេ គប្បីក្រៀវវាសំរាប់ចិញ្ចឹមធ្វើជាជ្រូកសាច់ ។
- កូនជ្រូកឈ្មោលគប្បីក្រៀវមុនវាមានអាយុបាន 1-2 អាទិត្យ ។
- កូនជ្រូកញីអាចក្រៀវពេលវាមានអាយុបាន 2-3 ខែ ។
- កូនជ្រូកអាយុបាន 45 ថ្ងៃ ឡើងទៅត្រូវចាក់វ៉ាក់សាំងការពារជំងឺប៉េស្តជ្រូកក្នុងករណីមានសុខភាពល្អ ។
- ចំពោះវ៉ាក់សាំងការពារជំងឺផ្សេងៗ បើសិនត្រូវចាក់អោយកូនជ្រូកគេត្រូវទទួលតាមការណែនាំអំពីបសុពេទ្យ ។

## ❽ បញ្ហាមូលហេតុបង្កនូវភាពរាគរូសទៅលើកូនជ្រូក និងការដោះស្រាយ

### ក. បញ្ហាមូលហេតុផ្សេងៗដែលបង្កនូវភាពរាគរូសរបស់កូនជ្រូក ៖

- បាក់តេរី (មេរោគឈ្មោះសាល់ម៉ូណែឡូស និងអេកូលី)

- ប៉ារ៉ាស៊ីត (ព្រូនក្នុងខ្លួន)
- មេជ្រូកកើតជំងឺរលាកដោះ រលាកស្បូន និងខ្វះទឹកដោះ
- គុណភាពចំណីអាហារអាក្រក់ (ប្រៃ ឈើសជាតិខ្លាញ់ ជាតិសរសៃ (សែ-លុយឡូសបង្កអោយរលាកផ្លូវរំលាយអាហារ) ។
- ផ្លាស់ប្តូរចំណីអាហារយ៉ាងប្រញាប់ប្រញាល់
- ស៊ីចំណីច្រើនហួស
- មេជ្រូករកណ្ដាលពេលកូននៅបៅដោះ
- ខ្វះឈាម
- ទ្រុងមានសំណើម និងត្រជាក់បណ្តាលអោយកូនជ្រូកបាត់បង់កំដៅក្នុងខ្លួន ។ ទ្រុងសើមក៏ជាលក្ខខ័ណ្ឌប្រកបអោយមេរោគរីកចំរើនផងដែរ ។

ខ. <u>ដំណោះស្រាយនៅពេលដែលកូនជ្រូករាគរូស</u> :

- រាយការណ៍ប្រាប់អ្នកបច្ចេកទេសបសុពេទ្យ ដើម្បីស្វែងរកមូលហេតុ
- ពិនិត្យអង្កេតដោយខ្លួនឯង និងកែប្រែបញ្ហាការខ្វះខាតបើសិនជាមាន : (<u>ឧទាហរណ៍</u> : ទ្រុងសើម ត្រជាក់ អោយស៊ីចំណីច្រើនហួស ខ្វះទឹកផឹក កូនជ្រូកផឹកទឹកក្រខ្វក់) ។
- បន្ថយបរិមាណចំណីអាហារ បើសិនជាមានការផ្លាស់ប្តូរចំណីអាហារអោយជ្រូកស៊ី គប្បីប្តូរសន្សឹមៗ : ថ្ងៃទី 1 = 25% ចំណីថ្មី ថ្ងៃទី 2 = 50% ថ្ងៃទី 3 = 75% ថ្ងៃទី 4 = 100% ។
- ផ្គត់ផ្គង់ទឹកស្អាតសំរាប់ជ្រូកផឹកគ្រប់គ្រាន់ ។

- បើសិនជាធ្ងន់ធ្ងរ ត្រូវប្រើប្រាស់ថ្នាំព្យាបាលអោយបានត្រឹមត្រូវតាមការណែនាំពីអ្នកបច្ចេកទេសបសុពេទ្យ ។

❸ <u>តម្រូវការអំពីទ្រុង</u>

ក. *រក្សាទ្រុងអោយមានកំដៅល្មម និងស្ងួតគឺពិតជាមានសារៈសំខាន់ណាស់ចំពោះកូនជ្រូក :*

- ទ្រុងជ្រូកមានសីតុណ្ហភាពត្រជាក់ ងាយស្រួលធ្វើអោយជ្រូកកើតជំងឺហើមស្ងួត និងរោគរាគរូស ។
- ទ្រុងសើមក៏ធ្វើអោយជ្រូកត្រូវត្រជាក់ ពិសេសគឺនៅពេលមានខ្យល់បក់ខ្លាំង ។

ខ. *កូនជ្រូកនៅបៅដោះត្រូវការសីតុណ្ហភាពសំរាប់កម្លៃងរស់នៅខាងក្រោមនេះ :*

- អាទិត្យដំបូង = 32 អង្សាសេ
- អាទិត្យទី 2 = 30 អង្សាសេ
- អាទិត្យទី 3 = 28 អង្សាសេ
- អាទិត្យទី 4 = 26 អង្សាសេ
- អាទិត្យទី 5 = 24 °C.

# ឯកសារយោង " REFERENCE "


- បទពិសោធន៍ចិញ្ចឹមជ្រូក
  - សាច់
  - មេជ្រូក
  - កូនជ្រូក
  - ជ្រូកបា

  ដោយបណ្ឌិត *NGVYEN XUAN BINH; 1996 (VN)*
- បច្ចេកទេសចិញ្ចឹមជ្រូក ដោយវិស្វករ *PHAM HUV DOANH; LUU Ky; HA NOI; 1996 (VN)*
- បច្ចេកទេសចិញ្ចឹមសត្វ ដោយបណ្ឌិត *HOANG ANH TUAN; 1993 (VN)*

## មន្ត្រីគណៈកម្មការអភិវឌ្ឍន៍ផលិតកម្ម និងបសុព្យាបាលខេត្តតំបន់ជាយដែន

| ល.រ | នាមគោត្តនាម | មុខងារ | តួនាទី |
|---|---|---|---|
| 1. | អ៊ុច សារ៉ន | ប្រធានការិ ផ.ប ខេត្តបន្ទាយមានជ័យ | ប្រធាន |
| 2. | សៅ ណើម | ប្រធានការិ ផ.ប ខេត្តបាត់ដំបង | អនុប្រធាន |
| 3. | ម៉ែន ហុង | អនុប្រធានការិ ផ.ប ខេត្តពោធិសាត់ | លេខាធិការ |
| 4. | ប៊ិន ស៊ុណាភ៉ា | មន្ត្រីការិ ផ.ប ខេត្តពោធិសាត់ | សមាជិក |
| 5. | សួន សំអាន | មន្ត្រីការិ ផ.ប ខេត្តសៀមរាប | សមាជិក |
| 6. | ជ្រុំ វិច | មន្ត្រីការិ ផ.ប ខេត្តសៀមរាប | សមាជិក |
| 7. | ណឹម ឆវ្លី | មន្ត្រីការិ ផ.ប ខេត្តសៀមរាប | សមាជិក |
| 8. | ប៉ាង វណ្ណសេដ្ឋ | មន្ត្រីការិ ផ.ប ខេត្តបន្ទាយមានជ័យ | សមាជិក |
| 9. | សេង ហាក់ | មន្ត្រីការិ ផ.ប ខេត្តពោធិសាត់ | សមាជិក |
| 10. | អ៊ីវ វណ្ណា | មន្ត្រីការិ ផ.ប ខេត្តបន្ទាយមានជ័យ | សមាជិក |
| 11. | ទឹម ភាន | មន្ត្រីការិ ផ.ប ខេត្តបាត់ដំបង | សមាជិក |
| 12. | សៀង សុថាវរៈ | មន្ត្រីការិ ផ.ប ខេត្តបាត់ដំបង | សមាជិក |
| 13. | យឹម សំណាង | មន្ត្រីលើកលែងហែវ៉េរ ខេត្តបាត់ដំបង | ទីប្រឹក្សា |
| 14. | សោម សួន | អនុប្រធាននាយកដ្ឋាន ផ.ប ភ្នំពេញ | ទីប្រឹក្សា |

**វាយកុំព្យូទ័រ (Computer) ដោយលោក ញូ ដាលី**